- ប្រភពទឹក ( ឈ្មោះទន្លេ ផ្ទៃរងទឹកភ្លៀង ស្ថានីយទឹកភ្លៀងជិតបំផុត)
- ប្រព័ន្ធស្រោចស្រព ( ចំនួនអាងទឹក និង មាឌអាង ប្រឡាយ ម៉ាស៊ីនបូមទឹក ។ល ។
- សហគមន៍កសិករប្រើប្រាស់ទឹក
- ដំណាំ ( ដំណាំសំខាន់ ដំណាំផ្សេងៗ)
- ផ្លូវចូល ( ចំងាយពីសាលាស្រុកដល់ចំណុចចាប់ផ្តើមរបស់ប្រឡាយមេ ស្ថានភាពផ្លូវថ្នល់)
- ឆ្នាំបញ្ចប់
- គំរោងថវិការ
- តួនាទីបច្ចុប្បន្ន

ពត៌មានខាងលើ និង ត្រូវចងក្រងនៅក្នុងតារាងជាបន្តបន្ទាប់ដោយ ម.ធ.ទ.ឧ (DWRAM) ហើយទិន្នន័យនឹងបញ្ចូលទៅក្នុងតារាងនៃកម្មវិធីកុំព្យូទ័រ ។

**តារាង បញ្ជីសារពើភ័ណ្ឌនៃគំរោងស្រោចស្រពដែលមានស្រាប់ (ទំរង់ 1)**

| លេខរៀង | ខេត្ត | ស្រុក | ឃុំ | ឈ្មោះប្រព័ន្ធ | ផ្ទៃស្រោចស្រព ( ហ.ត) | ប្រភពទឹក | | | ប្រព័ន្ធស្រោចស្រព | | | | | FWUC | ដំណាំ | | ផ្លូវចូល | | ឆ្នាំ | ថវិការ | តួនាទី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ឈ្មោះ | ផ្ទៃរងទឹកភ្លៀង ( គម$^2$ ) | ស្ថានីយទឹកភ្លៀង | ចំនួនអាងទឹក | មាឌអាងទឹក | ប្រឡាយ | ម៉ាស៊ីនបូមទឹក | ផ្សេងៗ | | សំខាន់ | ផ្សេងៗ | ចំងាយទៅកាន់សាលាស្រុក ( គម) | ស្ថានភាព | | | |
| | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | |

1 ទំរង់នេះមាននៅក្នុងតារាងភ្ជាប់ 1 " ទំរង់សំរាប់ការវាស់ស្ទង់ និង ការអង្កេត " ដូច " ទំរង់ 1 " ដោយមានការណែនាំពីរបៀបបំពេញទំរង់

## 2.4 ការបង្ហាញ និង ផ្តល់អាទិភាព

ទទួលបានបញ្ជីសារពើភ័ណ្ឌនៃប្រព័ន្ធស្រោចស្រពដែលមានស្រាប់ បេក្ខភាពប្រព័ន្ធស្រោចស្រពត្រូវបានជ្រើសរើសតាមរយៈដំណើរការបង្ហាញវិធីការកំណត់ និង ធនធានអោយបានល្អប្រសើរបំផុត។ ប្រព័ន្ធគួរតែចែកជាប្រភេទទៅតាមខ្នាតរបស់វា (ធំ មធ្យម តូច) និង មុខងារបច្ចុប្បន្ន (សំរាប់ការស្តារ សំរាប់ការស្ថាបនា ឬ ជួសជុលឡើងវិញ) ។ ការបង្ហាញ និង កំណត់ប្រភេទនឹងមានពន្យល់បង្ហាញក្នុង រូបភាព2.2 ។

### 2.4.1 ការកំណត់ប្រភេទតាមផ្ទៃដីស្រោចស្រព

យោងតាមនិយមន័យរបស់ ក្រ.ធ.ទ.ឧ (MOWRAM) ប្រព័ន្ធស្រោចស្រពត្រូវកំណត់ប្រភេទតាមផ្ទៃដីរបស់វាដូចខាងក្រោមនេះ :

<u>ខ្នាតរបស់ប្រព័ន្ធស្រោចស្រព</u>

- ខ្នាតធំ : ផ្ទៃដីស្រោចស្រពលើសពី 5.000 ហ.ត
- ខ្នាតមធ្យម : ផ្ទៃដីស្រោចស្រពរវាង 200 ហ.ត និង 5.000ហ.ត
- ខ្នាតតូច : ផ្ទៃដីស្រោចស្រពតិចជាង 200 ហ.ត

ធនធានចាំបាច់ និង ថ្លៃសំរាប់ផែនការ និង ការងារគ្រោងអាស្រ័យលើខ្នាតគោលដៅរបស់គំរោង ។

### 2.4.2 មុខងារបច្ចុប្បន្ន

ប្រសិនបើប្រព័ន្ធស្រោចស្រពត្រូវបានថែទាំយ៉ាងល្អគ្រប់គ្រាន់ពិតប្រាកដនោះ វាមិនចាំបាច់ពោលពីការ ស្តារ ឬ ជួសជុលឡើងវិញនៃប្រព័ន្ធឡើយ ។

ប្រសិនបើប្រព័ន្ធកំពុងត្រូវបានដំណើរការដោយខ្វះមុខងារនៃសំណង់ ឬ មិនបានដំណើរការជាបណ្តោះអាសន្ន (ក្នុងរយៈពេលពីរ បីឆ្នាំ) ដោយសារភាពយ៉ាប់យ៉ឺនរបស់សំណង់នោះ ការងារស្តារឡើងវិញគួរបានពិចារណា ។

ប្រព័ន្ធដែលបានបោះបង់ចោល ដោយមិនមានមុខងារលើសពី ប្រាំ (5)ឆ្នាំ នឹងត្រូវបានសាងសង់ឡើងវិញដោយសន្មត់ថាភាពយ៉ាប់យ៉ឺនយ៉ាងធ្ងន់ធ្ងរ ដោយគ្មានការងារថែទាំក្នុងរយៈពេលយ៉ាងយូរ ។

យោងទៅលើអត្ថន័យខាងលើ ត្រូវបានកំណត់ប្រភេទបេក្ខភាពនៃគំរោង ។

### 2.4.3 ការបញ្ជាក់ទីតាំងការដ្ឋាន

បន្ទាប់មកបេក្ខភាពនៃគំរោងគួរបានពិនិត្យនៅការដ្ឋាន ។ តាមចំណុចដែលត្រូវត្រួតពិនិត្យជាបន្តបន្ទាប់គឺ :

ចំណុចត្រួតពិនិត្យនៅការដ្ឋាន

- ការបញ្ជាក់ពត៌មាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ( ទំហំ ចំនួន ។ល។)
- ដីដែលប្រើប្រាស់បច្ចុប្បន្ននៅក្នុងតំបន់ស្រោចស្រព ( ដាំដុះ ឬ អត់ ប៉ុន្មានភាគរយ? ដីប្រើប្រាស់នៅក្នុងអាងទឹក ដាំដុះឬអត់?)
- ដីដែលខូចស្រាប់ ( ដីលិចទឹក ដីនៅក្រោមសំណង់ ។ល។)
- ការប៉ះពាល់ជាអវិជ្ជមានផ្សេងៗ
- ធនធានទឹក ( ការប៉ាន់ស្មានត្រួសៗធារទឹកតាមរដូវ? ដែលមានរាល់ឆ្នាំ?)
- សេចក្តីត្រូវការរបស់អ្នកទទួលផលប្រយោជន៍ ( ស្មើខ្លាំង ឬ អត់)
- ទំហំការងារ ( តូច, ធំ)
- បញ្ហាផ្សេងៗ និង កំហិតកំណត់

## 2.4.4 ការផ្តល់អាទិភាពនៅថ្នាក់ខេត្ត

ពិចារណាលើកំណត់ចរិការអភិវឌ្ឍន៍ និង ភាពបន្ទាន់របស់គំរោងនីមួយៗ អាទិភាពគួរផ្តល់អោយបេក្ខភាពគំរោង ។ គណៈកម្មាការអភិវឌ្ឍន៍ខេត្ត (PRDC) នឹងរៀបចំការប្រជុំមួយ សំរាប់បំពេញគោលបំណងនេះ ។ អ្នកចូលរួមក្នុងអង្គប្រជុំមាន :

អ្នកចូលរួមក្នុងអង្គប្រជុំសំរាប់ការផ្តល់អាទិភាពនៅក្នុងថ្នាក់ខេត្ត

- គណៈអធិបតី : អភិបាលខេត្ត
- លេខាធិការដ្ឋាន : ម.ធ.ទ.ឧ (DWRAM)
- តំណាងមកពីការិយាល័យរដ្ឋាភិបាល ( ការិយាល័យខេត្ត)
- តំណាងមកពីស្រុកដែលពាក់ព័ន្ធ
- ទីចាត់ការនៃសេវាកម្មសាធារណៈខេត្ត (MAFF MRD ។ល។)

តំណាងរបស់អ្នកទទួលផលប្រយោជន៍ ដូចជាមេឃុំ និង ភូមិ ស.ក.ប.ទ (FWUC) ។ល។ នឹងត្រូវអញ្ជើញចូលរួមក្នុងអង្គប្រជុំ ។ ក្រោយការផ្តល់អាទិភាពជាបន្ទាប់ ឬ កំណត់ថ្នាក់របស់អាទិភាព នឹងផ្តល់អោយគំរោងនីមួយៗ ( យោង **ទំរង់ 2**) ។ មូលដ្ឋានរបស់អាទិភាពខ្ពស់គួរតែបានសរសេរនៅក្នុងទំរង់ ។

## 2.4.5 ការជ្រើសរើសនៅថ្នាក់កណ្តាល

លទ្ធផលនៃការផ្តល់អាទិភាពនៅថ្នាក់ខេត្តត្រូវបានបញ្ជូនទៅនាយកដ្ឋានផែនការរបស់ ក្រ.ធ.ទ.ឧ (MOWRAM) នាយកដ្ឋានផែនការ នឹង រៀបចំអង្គប្រជុំមួយនៅថ្នាក់កណ្តាលដើម្បីជ្រើសរើសគំរោងយោងទៅលើនយោបាយអភិវឌ្ឍន៍ជាតិ ។ ក្រោយពេលបានប៉ាន់ស្មានតំលៃសំរាប់ផែនការ និង ការងារគ្រោង

MOWRAM នឹងធ្វើការរៀបចំថវិការសំរាប់មូលនិធិក្នុងស្រុក ឬ អន្តរជាតិ ។

## 2.5 តំរូវការទិន្នន័យ និង ពត៌មាន

តំរូវការទិន្នន័យ និង ពិតមានដើម្បីអនុវត្តផែនការ និង ការគ្រោងបានសង្ខេបជាបន្ទុបន្ទាប់តាម :

**តារាង តំរូវការទិន្នន័យ និង ពត៌មានសំរាប់ផែនការ និង ការគ្រោង**

| ប្រភេទ | ទិន្នន័យ/ពិតមាន | ប្រភព |
|---|---|---|
| ស្ថានភាពឋានលេខា | ផែនទី (1:100,000)<br>ផែនទី (1:5,000-10,000)<br>ផែនទី (1:100-សំណង់)<br>រូបថតពីលើអាកាស | ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>ផែនទីសាស្ត្រពីលើអាកាស<br>វាស់ស្ទង់ទីវាល<br>ក្រសួងសាធារណការ និង ដឹកជញ្ជូន (MPWT) |
| សេដ្ឋកិច្ចសង្គម | សៀវភៅស្ថិតិប្រចាំឆ្នាំ<br>ជំរឿនចំនួនប្រជាជនទូទៅ<br>ផែនការអភិវឌ្ឍន៏ខេត្ត<br>ស្ថិតិដែលចងក្រងនៅស្រុក<br>ស្ថិតិដែលចងក្រងនៅឃុំ<br>ជំរឿនថ្នាក់ភូមិ ឆ្នាំ1998<br>សៀវភៅគ្រួសារភូមិ | ក្រសួងផែនការ<br>ក្រសួងផែនការ<br>ការិយាល័យខេត្ត<br>ការិយាល័យស្រុក<br>ការិយាល័យឃុំ<br>ក្រសួងផែនការ (CD-ROM)<br>ប្រធានភូមិ |
| កសិកម្ម<br>សេដ្ឋកិច្ចកសិកម្ម<br>ការវាយតំលៃគំរោង | ផែនទីដីរបស់តំបន់ដាំដុះស្រូវ<br>ផែនការអភិវឌ្ឍន៏កសិកម្ម<br><br>ថ្លៃសំភារៈប្រើប្រាស់ (ចូល)<br>ថ្លៃផលិតផលនៅកសិដ្ឋាន<br>ដំណាំគំរូបច្ចុប្បន្ន<br>សេដ្ឋកិច្ចគ្រួសារ<br><br>ដីដែលអាចដាំដុះ<br><br>សេវាកម្មទ្រទ្រង់ | នាយកដ្ឋានភូមិសាស្ត្រ IRIC<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF)<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (សំណាវាស់ស្ទង់)<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (គំរូវាស់ស្ទង់)<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (MAFF NGO ។ល ។) |
| ជលសាស្ត្រ និង ទឹកប្រើប្រាស់ | ផែនទីជលសាស្ត្រ-ភូគព្ភសាស្ត្រ<br>ទឹកភ្លៀង កំពស់ទឹកទន្លេ<br>ទិន្នន័យធារទឹក<br>គុណភាពទឹក<br>ការកករងកករល្បប់<br>រូបមន្តពិសោធន៍សំរាប់ទឹកដែលហៀរចេញ និង ទឹកជំនន់ | នាយកដ្ឋានភូមិសាស្ត្រ IRIC<br>MOWRAM DWRAM<br>នឹងការវាស់វែងការដ្ឋាន MOWRAM<br>MRD MOE និងផ្នែកវាស់វែង<br>MOWRAM ផ្នែកវាស់វែង ការសិក្សា<br>ការរៀបចំរបាយការណ៍របស់ការងារពីមុន |

| ប្រភេទ | ទិន្នន័យ/ពិតមាន | ប្រភព |
|---|---|---|
| ភូគព្ភសាស្ត្រ និង ការងារដី | ផែនទីវិស្វកម្ម<br>វិស្វកម្មខួងដី<br>ពិសោធន៍សំភារៈ និង ការប៉ាន់ស្មានមាឌ | នាយកដ្ឋានភូមិសាស្ត្រ IRIC<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា |
| ការស្រោចស្រព និង ដោះទឹក | បញ្ជីសារពើភ័ណ្ឌប្រឡាយស្រោចស្រព<br><br>បញ្ជីសារពើភ័ណ្ឌសំណង់<br><br>បញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និង ទំនប់ | នឹងត្រូវប្រមូលដោយផ្នែកវាស់ស្ទង់ទីវាល<br>នឹងត្រូវប្រមូលដោយផ្នែកវាស់ស្ទង់ទីវាល<br>នឹងត្រូវប្រមូលដោយផ្នែកវាស់ស្ទង់ទីវាល |
| ការគ្រោង | ស្តង់ដារការរៀបចំ គំរូគ្រោង ឬ ស្តង់ដារគ្រោង<br>តំលៃសំភារៈ ឧបករណ៍ ពលកម្ម ។ល។ | MOWRAM, MPWT,MRD ,នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា |
| ស្ថាប័ន | FWUC និង សកម្មភាព<br>ក្រុមកសិករ<br>VDC និង សកម្មភាព | នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (DWRAM ភូមិ)<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (MAFF VDC ភូមិ)<br>នឹងត្រូវវាស់ស្ទង់ក្នុងការសិក្សា (DRD ស្រុក ភូមិ) |
| បរិស្ថាន | ច្បាប់ និង អនុក្រិត្យអំពី EIA<br>ការត្រួតពិនិត្យបរិស្ថានបឋម<br>ប៉ាន់ស្មានការប៉ះពាល់បរិស្ថាន | MOE<br>នឹងត្រូវធ្វើក្នុងការសិក្សា<br>នឹងត្រូវធ្វើក្នុងការសិក្សា (បើត្រូវការ) |
| ផែនការអ្នកចូលរួម | សំណាកស្ទាបស្ទង់គ្រួសារកសិករ<br>ការប៉ាន់ស្មានត្រួសៗពីជនបទ<br>ប្រជុំស្តាប់មតិសាធារណៈនៅដំណាក់កាលផែនការ<br>ប្រជុំភូមិ<br>ប្រជុំស្តាប់មតិសាធារណៈនៅដំណាក់កាលគ្រោង | នឹងត្រូវធ្វើក្នុងការសិក្សា<br>នឹងត្រូវធ្វើក្នុងការសិក្សា<br>នឹងត្រូវធ្វើក្នុងការសិក្សា<br><br>នឹងត្រូវធ្វើក្នុងការសិក្សា<br>នឹងត្រូវធ្វើក្នុងការសិក្សា |

# ជំពូក 3 សេដ្ឋកិច្ចសង្គម

## 3.1 លក្ខណៈទូទៅ

ដើម្បីយល់ឱ្យច្បាស់លាស់ពីស្ថានភាពសេដ្ឋកិច្ចសង្គម បញ្ហា និង ឧបសគ្គ នៃការអភិវឌ្ឍន៍ក្នុងតំបន់ដែលកំណត់ ទិន្នន័យសេដ្ឋកិច្ចសង្គមដែលមានគួរតែប្រមូលផ្តុំ និង វិភាគហើយការស្ទាបស្ទង់បន្ថែមគួរតែធ្វើនៅក្នុងតំបន់គំរោង ។ ទិន្នន័យសេដ្ឋកិច្ចសង្គមជាតិ និង ថ្នាក់ខេត្តមួយចំនួនដែលមានត្រូវបានចងក្រង និង បោះពុម្ពផ្សាយដោយក្រសួងផែនការ ហើយទិន្នន័យតាមមូលដ្ឋានមួយចំនួនធំត្រូវបានចងក្រងនៅមន្ទីរខេត្ត ឬ ស្រុក ។ ស្ថិតិថ្នាក់ជាតិ និង ខេត្តនឹងត្រូវប្រើសំរាប់ចែកប្រភេទផ្តល់អាទិភាព និង ជ្រើសរើសបណ្តាខេត្តដែលមានកំរិតទីទាល់ក្រ និង ផលិតកម្មទាប ។ល ។

ទិន្នន័យសេដ្ឋកិច្ចសង្គមថ្នាក់មូលដ្ឋានក៏នឹងត្រូវយកមកប្រើដើម្បីកំណត់គោលដៅតាមលំដាប់លំដោយ និង ការវាយតំលៃគំរោង ។

## 3.2 សេដ្ឋកិច្ចតំបន់ និង ស្ថានភាពសង្គម

### 3.2.1 ថ្នាក់ជាតិ និង ថ្នាក់ខេត្ត

ស្ថិតិសេដ្ឋកិច្ចសង្គមចំបង និង របាយការណ៍អាចរកបាននៅថ្នាក់ជាតិ និង ខេត្តដូចបានចុះបញ្ជីក្នុងតារាងខាងក្រោម :

**តារាង ស្ថិតិសេដ្ឋកិច្ចសង្គមចំបងនៅថ្នាក់ជាតិ**

| ឈ្មោះការបោះពុម្ពផ្សាយ | មាតិកា | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| សៀវភៅស្ថិតិប្រចាំឆ្នាំកម្ពុជា | ចំនួនប្រជាជន និង ប្រជាសាស្ត្រ ការងារ និង ប្រាក់បំណាច់តំលៃ និង អត្រាប្តូរប្រាក់ចំណូល និងចំណាយ កសិកម្ម នេសាទ និង រុក្ខា ។ ល ។ | ក្រសួងផែនការ |
| លំដាប់តំលៃប្រើប្រាស់ | ការបោះពុម្ពផ្សាយប្រចាំខែស្តីអំពីតំលៃដែលអ្នកប្រើប្រាស់ចំណាយលើវត្ថុប្រើប្រាស់ចាំបាច់ | ក្រសួងផែនការ |
| គណនីជាតិរបស់កម្ពុជា 1996-1999 | ចំណូលចំណាយជាតិ-ពាណិជ្ជកម្មរបស់កម្ពុជា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អត្តសញ្ញាណកម្មតំបន់ក្រីក្រក្នុងប្រទេសកម្ពុជា | ផែនទីភាពក្រីក្រនៅកម្ពុជា លទ្ធផល និង ការវិភាគរបស់ការជំរឿនចំនួនប្រជាជនជាតិ (1998) និង ការស្ទាបស្ទង់សេដ្ឋកិច្ចសង្គមកម្ពុជា 1999 កំរិតភាពក្រីក្រ ។ល ។ | WFP ក្រសួងផែនការ UNDP |
| ឯកសារភាពក្រីក្រនៅកម្ពុជា | លទ្ធផលនៃការស្ទាបស្ទង់សេដ្ឋកិច្ចសង្គមកម្ពុជា 1993 – 94 ការកំណត់កំរិតភាពក្រីក្រសំរាប់កម្ពុជា ចរិតលក្ខណៈនៃភាពក្រីក្រ | ការពិភាក្សារបស់ធនាគារពិភពលោក លិខិតលេខ 373 |
| ផែនការអភិវឌ្ឍន៍ 5ឆ្នាំ 2001-2005 ខេត្តតាកែវ | គោលដៅអភិវឌ្ឍន៍ និង ផែនការរបស់តំបន់នីមួយៗក្នុងខេត្តតាកែវ | មន្ទីរខេត្តតាកែវ ក្រសួងផែនការ |

### 3.2.2 ថ្នាក់ស្រុក និង ថ្នាក់ឃុំ

មន្ទីរស្រុកមានមន្ត្រីរដ្ឋបាល និង មន្ត្រីជំនាញដែលចាត់តាំងដោយទីភ្នាក់ងារដែលពាក់ព័ន្ធ ។

ឧទាហរណ៍ ក្រ.ធ.ន.ឧ. (MOWRAM) ម.ធ.ន.ឧ.ខេត្ត (DWRAM) មានមន្ត្រីមួយចំនួននៅមន្ទីរស្រុកនីមួយៗ ពួកគេប្រមូលទិន្នន័យមូលដ្ឋាន និង ពត៌មានយល់ដឹងពីសំណូមពរ និង តម្រូវការរបស់ប្រជាជន ហើយលើកស្នើផែនការអភិវឌ្ឍន៍ស្រុកទៅ DWRAM (MOWRAM) ។

ឃុំស្ថិតនៅកំរិតក្រោមបំផុតនៃមន្ត្រីរដ្ឋបាលក្រោមការគ្រប់គ្រងរបស់មន្ទីរស្រុក ដែលជាទូទៅមានពី 4 ទៅ 15 ឃុំ ។ មន្ទីរឃុំប្រមូល និង ចងក្រងទិន្នន័យសេដ្ឋកិច្ចសង្គមដែលបានមកពីភូមិ ហើយផ្ញើទៅមន្ទីរស្រុក ។ សំរាប់គំរោងស្រោចស្រពតូចៗ ដែលមានទីតាំងស្ថិតនៅក្នុងឃុំនោះ ត្រូវប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមនៅថ្នាក់ឃុំឱ្យបានរួសរាន់ និង ត្រឹមត្រូវ ។ ទោះបីជាយ៉ាងណានេះ ក៏មន្ទីរឃុំមួយចំនួនពុំបានរក្សាក្រមទិន្នន័យ ឬ ធ្វើមិនឱ្យប្រែប្រួលជានិច្ចឡើយ ដូច្នេះការស្ទាបស្ទង់បន្ថែមដោយបញ្ជីសំនួរ និង សម្ភាសន៍ (ទៅកាន់បុគ្គលិកឃុំ) ជាញឹកញាប់ត្រូវបានធ្វើឡើង ។

នៅក្នុងខេត្ត ស្រុក និង ឃុំជាច្រើនបណ្តាគំរោងត្រូវបានដឹកនាំធ្វើដោយអង្គការអន្តរជាតិ (IOs) និង អង្គការក្រៅរដ្ឋាភិបាល NGOs ដែលមានការិយាល័យនៅការដ្ឋានរបស់គំរោងត្រូវបានដាក់បញ្ចូល ។ គំរោងទាំងនោះថែមទាំងបានប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមនៅថ្នាក់ស្រុក ឬ ទាបជាង ។ វាជាប្រការមានប្រយោជន៍ដែលត្រូវប្រមូលពត៌មានទាំងអស់នេះពីអង្គការទាំងនោះ ។

### 3.2.3 ថ្នាក់ភូមិ

ការងារអភិវឌ្ឍន៍ភាគច្រើនដែលអនុវត្តតែងតែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយភូមិ ។ ចំណុចចាប់ផ្តើមនៃការអភិវឌ្ឍន៍ គួរតែបង្កើតឡើងនៅភូមិដោយយកចិត្តទុកដាក់ចំពោះការចូលរួមព្រមទាំងការសន្យាទ្រទ្រង់ការអភិវឌ្ឍន៍ ។

នៅថ្នាក់ភូមិ ពត៌មានសេដ្ឋកិច្ចសង្គមជាមូលដ្ឋានត្រូវបានចងក្រងក្នុង "សៀវភៅបញ្ជីអ្នកភូមិ" ដែលរក្សាទុកដោយប្រធានភូមិ ។ ពត៌មានដែលចងក្រងក្នុងសៀវភៅតែងតែខុសគ្នាពីភូមិមួយទៅភូមិមួយទៀត ពត៌មានជាបន្តបន្ទាប់នឹងត្រូវបញ្ចូលជាលក្ខណៈទូទៅ :

- ឈ្មោះអ្នកភូមិតាមគ្រួសារ
- មេគ្រួសារនីមួយៗ និង
- អាយុ ភេទ ប្រវត្តិការសិក្សា សាសនា មុខរបរ ។ល ។

តាមពត៌មានទាំងអស់នេះគេ និង អាចយល់ច្បាស់លាស់ពីប្រវត្តិមនុស្សសាស្ត្រ ក៏ប៉ុន្តែពត៌មានដទៃទៀត ដូចជាការកាន់កាប់ដី ស្ថានភាពសេដ្ឋកិច្ច និង ត្រូវបានប្រមូលតាមរយៈបញ្ជីសំនួរ និង សម្ភាសន៍ទៅតាមគ្រួសារគោលដៅ ។ ជាទូទៅនៅតាមភូមិនីមួយៗតែងតែបែងចែកជាក្រុម ។ ការស្ទាបស្ទង់ដែលឱ្យផលគួរតែទំនាក់ទំនងជាមួយប្រធានភូមិ និង ប្រធានក្រុម ។

ការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមដោយថ្នាក់រដ្ឋបាលត្រូវបានសង្ខេបក្នុង រូបភាព 3.1 ។

## 3.3 ការស្ទាបស្ទង់លំអិត

### 3.3.1 ការស្ទាបស្ទង់តាមឃុំ

ដើម្បីយល់ឱ្យបានច្បាស់លាស់ពីស្ថានភាពសេដ្ឋកិច្ចសង្គមជាទូទៅក្នុងតំបន់គោលដៅ ការស្ទាបស្ទង់មតិតាមឃុំគឺជាវិធីមួយមានប្រសិទ្ធិភាពបំផុត ។ ដូចដែលបានរៀបរាប់ខាងលើទិន្នន័យសេដ្ឋកិច្ចសង្គមនៅថ្នាក់ឃុំមិនបានចងក្រងជាក្រមជានិច្ចទេ ហើយការស្ទាបស្ទង់បន្ថែម ឬ បង្គ្រប់ (សម្ភាសន៍ដោយមានបញ្ជីសំនួរ) និងត្រូវការជាញឹកញាប់ ។ ប្រការដែលត្រូវប្រមូលតាមរយៈការស្ទាបស្ទង់តាមឃុំមានដូចខាងក្រោម :

ប្រការសំរាប់ស្ទាបស្ទង់តាមឃុំ

- ពត៌មានទូទៅ ( ផ្ទៃដី រដ្ឋបាល ចំនួនប្រជាជន ចំនួនគ្រួសារ ។ល ។)
- ស្ថានភាពការរស់នៅ ( ផ្លូវចូល ទឹកផឹក មណ្ឌលសុខភាព និង សេវាកម្ម ចំនួនសាលា និង គ្រូបង្រៀន អត្រាអ្នកចេះអក្សរ អគ្គិសនី ។ល។)
- ការប្រើប្រាស់ និង កាន់កាប់ដី
- កសិកម្ម ( ផលិតកម្ម និង ទិន្នផល ការពង្រីកសេវាកម្ម បសុសត្វ និង នេសាទ ។ល ។)
- សេដ្ឋកិច្ចកសិកម្ម ( ថ្លៃផលិតកម្ម ថ្លៃចំណូលដំណាំ ថ្លៃដំណាំនៅចំការ និង ទីផ្សារ ផលិតផល កសិកម្ម សេវាឥណទានជនបទ ។

សំណាកបញ្ជីសំនួរសំរាប់ស្ទាបស្ទង់នៅតាមឃុំមានបង្ហាញក្នុងទំរង់ 3 ក្នុងតារាងភ្ជាប់ 1 ។

### 3.3.2 ស្ទាបស្ទង់ចំនួនគ្រួសារកសិករ

#### (1) ប្រភេទស្ទាបស្ទង់

ដើម្បីយល់ឱ្យបានច្បាស់លាស់ស្ថានភាពសេដ្ឋកិច្ចសង្គមលំអិត និង ជាក់លាក់នៃតំបន់គោលដៅការស្ទាបស្ទង់ចំនួនគ្រួសារត្រូវបានធ្វើឡើង ។ ការស្ទាបស្ទង់មានគំរូវាស់ស្ទង់ និង ការវាស់ស្ទង់សំរាប់គ្រួសារទាំងអស់ ។

សំណាកនៃការស្ទាបស្ទង់ត្រូវបានធ្វើសំរាប់គំរោងធំៗ ដែលមានផ្ទៃដីគ្រប់ខ្ទាតដណ្តប់លើភូមិមួយចំនួនក្នុងឃុំ ឬ តំបន់រដ្ឋបាលធំៗ ។ ចំពោះការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតតូចៗ ហើយដែលតំបន់នោះស្ថិតនៅតែក្នុងភូមិមួយ ការស្ទាបស្ទង់សំរាប់គ្រួសារទាំងអស់ត្រូវគេយកចិត្តទុកដាក់ធ្វើ មិនមែនគ្រាន់តែការប្រមូល និងចងក្រងទិន្នន័យ ប៉ុន្តែក៏សំរាប់ផែនការចូលរួមដែរ ។ គំរូសំណាកស្ទាបស្ទង់ក៏ពឹងផ្អែកទៅលើពេលវេលា និងធនធានដែលនឹងត្រូវ លៃលកឱ្យជាក់លាក់ផងដែរ <u>ប៉ុន្តែយ៉ាងហោចណាស់ក៏មានសំណាកមួយ ( គ្រួសារ) សំរាប់ភូមិមួយដែរ</u> ។

#### (2) ក្រុមស្ទាបស្ទង់

ការពិចារណាទៅលើការងារចំបងរបស់គ្រួសារ ការស្ទាបស្ទង់គួរធ្វើឡើងជាក្រុម ។ ក្រុមស្ទាបស្ទង់នឹងមានអ្នកសំរបសំរួលម្នាក់ និង ជាប្រធានក្រុមព្រមទាំងសំភាសន៍ម្នាក់ ។ អ្នកសំរបសំរួល និង ជាប្រធានក្រុម

គួរតែមាន ប្រវត្តិការសិក្សាពីសង្គមវិជ្ជាសេដ្ឋកិច្ច ឬ អភិវឌ្ឍន៍សហគមន៍ និង បទពិសោធសំរាប់ការស្ទាបស្ទង់គ្រួសារ ឬ ក៏ផែនការចូលរួម ។

ការស្ទាបស្ទង់គួរត្រូវធ្វើឡើង ពីរ រឺ បីក្រុម ។ មុនពេលធ្វើការស្ទាបស្ទង់អ្នកសំរបសំរួលព្រមទាំងជាប្រធានក្រុម គួរតែធ្វើការណែនាំ និង បណ្តុះបណ្តាលការងារដល់អ្នកសំភាសន៍ ។

អ្នកសំភាសន៍ម្នាក់គួររ៉ាប់រងអ្នកឆ្លើយតប 50 នាក់ ហើយនឹងធ្វើសម្ភាសន៍ជាមួយអ្នកឆ្លើយតបបាន 5 នាក់ ក្នុងមួយថ្ងៃ ។ ការបង្កើតក្រុមព្រមទាំងតួនាទីរបស់អ្នកសំរបសំរួល និង ជាប្រធានក្រុម ព្រមទាំងអ្នកសំភាសន៍ ថានឹងបង្ហាញក្នុង រូបភាព 3.2 ។

### (3) ការជ្រើសរើសអ្នកឆ្លើយតប

ត្រូវយកចិត្តទុកដាក់នឹងចំនួនអ្នកឆ្លើយតប (មានសំណាក ពីរ បី ក្នុងមួយភូមិ[1]) សំណាកគួរតែត្រូវធ្វើ ឡើងដោយប្រុងប្រយ័ត្នកុំឱ្យមានលំអៀង ។ ប្រការត្រឹមត្រូវដើម្បីជ្រើសរើសសំណាកគ្រួសារដោយយោងទៅ លើលទ្ធផលនៃការស្ទាបស្ទង់តាមឃុំ ក៏ប៉ុន្តែគួរតែជ្រើសរើសការរៀបចំតាមលំដាប់អក្សរឱ្យបានច្បាស់លាស់ដូច ជាគ្រួសារអ្នកមាន គ្រួសារអ្នកក្រ មេគ្រួសារជាស្ត្រីមេម៉ាយ ។ល។

## 3.4 ការចងក្រងទិន្នន័យ

លទ្ធផលនៃការស្ទាបស្ទង់សេដ្ឋកិច្ចសង្គម គួរតែត្រូវបានត្រួតពិនិត្យ និង ចងក្រងក្នុងទម្រង់មួយដែលមានប្រភពពិតមានផ្សេងៗពីគ្នា គឺការបោះពុម្ពផ្សាយស្ថិតិ និង លទ្ធផលស្ទាបស្ទង់គ្រួសារ និង ជាជំនួយសំរាប់ស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់គោលដៅ ។

សំណាកទម្រង់សំរាប់ចងក្រងការស្ទាបស្ទង់គ្រួសារ និង បង្ហាញ ក្នុងទម្រង់ 4 ក្នុងតារាងភ្ជាប់ I ។

[1] ក្នុងភូមិមួយមានគ្រួសារពី 1 ដល់ 3767

# ជំពូក 4 កសិកម្ម

## 4.1 ទិន្នន័យ និង ពត៌មានដែលត្រូវការ

ផែនការស្រោចស្រព និង ដោះទឹកនឹងត្រូវរៀបចំយ៉ាងជាក់លាក់ដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍន៍កសិកម្មដូចបង្ហាញខាងក្រោម :




**រូបភាព ទិន្នន័យ/ពត៌មានដែលត្រូវការសំរាប់អភិវឌ្ឍន៍ការស្រោចស្រព**

ចំពោះគំរោងស្រោចស្រពធំៗប្រការចាំបាច់ គឺត្រូវគិតពីតុល្យភាពស្បៀងក្នុង/ជុំវិញតំបន់គំរោង ។ ឧទាហរណ៍ ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតធំនៅតំបន់ខ្វះខាតស្បៀងដែលនឹងត្រូវកែលំអយ៉ាងខ្លាំងក្លាលើកំរិតនៃការប្រើប្រាស់ខ្លួនឯង និង ជីវភាពប្រជាជន នៅពេលដែលផលស្រូវលើសពីសេចក្តីត្រូវការការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពនឹងបង្កើនប្រាក់ចំណូលរបស់កសិករ ។ ក្នុងករណីនេះត្រូវយកចិត្តទុកដាក់ពីទិដ្ឋភាពទីផ្សារ និង ការប៉ះពាល់ដល់តំបន់នៅជុំវិញផង ។

ចំពោះការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតតូច និង មធ្យម ជាពិសេសចំពោះគំរោងការស្តារ និង សាងសង់ឡើងវិញ ដាំដុះគំរូបច្ចុប្បន្ន និង គោលបំណងរបស់កសិករ ម៉្យាងវិញទៀតដំណាំណាដែលគេចូលចិត្តជាងគេគួរតែត្រូវធ្វើតាមគំរូដាំដុះបានស្នើឡើង ។ ទោះបីជាយ៉ាងណាក៏ដោយ ការណែនាំបង្ហាញពីដំណាំដែលមានតំលៃខ្ពស់ដែលកសិករមិនធ្លាប់ស្គាល់ ប៉ុន្តែអាចធ្វើឱ្យប្រសើរឡើងប្រាក់ចំណូលរបស់ពួកគាត់ ដីដាំដំណាំ និង ទំហំដីសមស្របសំរាប់ដាំដំណាំ ជំនាញដាំដុះរបស់កសិករ សេវាទ្រទ្រង់បច្ចុប្បន្នដែលអាចរកបាន និង ទុនចំណាយកសិកម្ម ដូចជាការកែលំអពូជ ជីធម្មជាតិ ។ល។ ក៏គួរតែយកចិត្តទុកដាក់ផងដែរ ។

ពត៌មាន និង ទិន្នន័យភាគច្រើនអំពីកសិកម្ម និង ការអនុវត្តន៍ការដាំដុះគួរតែត្រូវបានប្រមូលក្នុងតំបន់គោលដៅដោយការធ្វើសម្ភាសន៍ ឬ ក៏តាមរយៈការស្ទាបស្ទង់មតិសាធារណៈជនផងដែរ ។ ទំរង់ 5 ក្នុងតារាងភ្ជាប់ 1 គឺជាតារាងគំរូនៃការស្ទាបស្ទង់ដែលអាចយកទៅប្រើដូចជាបញ្ជីសំនួរ ។

## 4.2 ដីដាំដុះ និង ទំហំដីធ្លី

### 4.2.1 ក្រុមដី និង ដីដាំដុះ

ដីដាំដុះក្នុងតំបន់ផលិតស្រូវត្រូវបានបែងចែកជា 10 ក្រុមដោយ "ចំណាត់ថ្នាក់ដីដាំដុះនៅកម្ពុជា" (CASC) ដែលធ្វើដោយកម្មវិធីកម្ពុជា អ៊ីរីអូស្ត្រាលី (CIAP) ក្នុងឆ្នាំ 1999 ។ គំរោងបានផ្តល់ផែនទីដីដាំដុះទូទាំងប្រទេស (1:900.000) និង សំរាប់ខេត្តមួយចំនួន (1:50.000) ដែលអាចរកបាននៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ (MAFF) ។ សេចក្តីលំអិតរបស់ក្រុមដីដាំដុះនឹងបង្ហាញនៅក្នុង "ដីប្រើប្រាស់សំរាប់ផលិតកម្មស្រូវនៅកម្ពុជា ក្បួនខ្នាតសំរាប់សំគាល់អត្តសញ្ញាណកម្ម និង គ្រប់គ្រងដី" នឹងមានសង្ខេបនៅក្នុង **តារាង 4-1** ។

ការវាស់ស្ទង់ដីគួរធ្វើសំរាប់ការសិក្សាលំអិត ឬ ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពថ្មី ។ ចំនួនទីតាំងសំណាកវាអាស្រ័យទៅលើការបែងចែកលំដាប់ដីដាំដុះ ដែលនឹងអាចបញ្ជាក់នៅក្នុងក្រុមដីដែលបានរៀបរាប់ខាងលើ ។

ចំពោះសំណាកដីត្រូវយកពីរ ឬ បីរណ្តៅក្នុងដីមួយក្រុម ។ ទំហំរណ្តៅសំណាកដីគួរតែមានទំហំ 1មx1មx1ម ហើយសំណាកដីនោះគួរតែយកពីស្រទាប់នីមួយៗ ។ រូបថត និង គំនូសព្រាងរបស់ស្រទាប់ដីបារចេញពីរណ្តៅវិភាគនីមួយៗ ។ ក្រោយពេលការយកសំណាកដីហើយសំណាកដីហើយនឹងត្រូវជ្រើសរើស

ប្រសិនបើដីទាំងនោះស្ថិតនៅក្រុមតែមួយ ។ សំណាកដីគំរូដែលជ្រើសរើសហើយត្រូវបញ្ជូនទៅមន្ទីរពិសោធន៍ សំរាប់ត្រួតពិនិត្យទៅតាមមុខការជាបន្តបន្ទាប់ :

- ដង់ស៊ីតេរបស់ដីជាដុំ
- វិភាគទំហំចុណ្ណភាគ ( បំណែកតូចៗ )
- pH
- បន្ទុកអគ្គិសនី (EC )
- នីត្រូហ្សែនសរុប ( T-N )
- អាម៉ូនីញ៉ូម នីត្រូហ្សែន ($NH_4$-N)
- នីត្រាត-នីត្រូហ្សែន ( $NO_3$-N)
- ហ្វូសហ្វាតសរុប (T-P)
- ហ្វូសហ្វាតដែលអាចមាន (Av-P)
- បណ្តូរការចុង (Ca Mg K Na)
- កំរិតបណ្តូរការចុង (CEC)
- កំរិតសំណើម

## 4.2.2 ដីដែលអាចដាំដំណាំបាន

ដីដែលអាចដាំដុះសំរាប់ប្រើប្រាស់ក្នុងកសិកម្ម ត្រូវបានកំណត់ដោយឈរលើមូលដ្ឋានផ្ទៃដីដាំដុះ ។ ដីដែលសមស្របនឹងដំណាំត្រូវបានសង្ខេបដូចខាងក្រោម :

**តារាង ដីដាំដុះ និង ដំណាំដែលអាចដាំបាន**

| ក្រុមដីដាំដុះ | | ដំណាំ | | ផលិតភាព |
|---|---|---|---|---|
| ទូទៅ | CASC | រដូវវស្សា | រដូវប្រាំង | |
| ដីល្បប់ទន្លេ/ដីល្បប់ពីតំបន់ខ្ពស់ | *ដីព្រៃខ្មែរ* | ស្រែ ដំណាំបន្ទាប់បន្សំ បន្លែ | ស្រូវ, ដំណាំបន្ទាប់បន្សំ, បន្លែ | ទាប |
| | *ដីប្រទះឡាង* | ស្រែ ដំណាំបន្ទាប់បន្សំ បន្លែ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | ទាប-មធ្យម |
| | *ដីបាកាន* | ស្រូវ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | មធ្យម |
| | *ដីតោកត្រប់* | ស្រូវ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | មធ្យម |
| | *ដីទួលសំរោង* | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | ខ្ពស់ |
| ដីល្បប់ទន្លេថ្មីៗ | *ដីកៀនស្វាយ* | ស្រូវ ឬ មានទឹកជំនន់ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | មធ្យម-ខ្ពស់ |
| | *ដីក្បាលពោធិ៍* | មានទឹកជំនន់ | ស្រូវ | ខ្ពស់ |
| | *ដីក្រគរ* | មានទឹកជំនន់ | ស្រូវ | ខ្ពស់ |
| ដីដែលនៅសល់ដោយធាតុអាកាស | *ដីឡាបានសៀក* | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | មធ្យម-ខ្ពស់ |
| | *ដីកំពង់សៀម* | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | ស្រូវ ដំណាំបន្ទាប់បន្សំ បន្លែ | មធ្យម-ខ្ពស់ |

**សំគាល់ : CASC : " ចំណាត់ថ្នាក់ដីដាំដុះនៅកម្ពុជា "**

### 4.2.3 ការប្រើប្រាស់ដី

ការប្រើប្រាស់ដីសំរាប់ដាំដំណាំគឺជាពត៌មានដ៏មានសារៈសំខាន់សំរាប់ផែនការកសិកម្ម ។ ការប្រើប្រាស់ទំហំដីធ្លី ( ផ្ទៃក្រឡា ) គួតែត្រូវបានបញ្ជាក់សំរាប់ប្រភេទជាបន្តបន្ទាប់ :

1. ដីដាំដុះ ( ផ្ទៃក្រឡាដាំដុះ )

    1.1 ដីស្រែ

    1.2 ដំណាំផ្សេងៗ

2. ដីព្រៃគុម្ពោតចុល្លព្រឹក្ស ព្រៃឈើ ភ្នំ

3. ដីលំនៅដ្ឋាន និង ដីតំបន់សំណង់អាគារ

4. ដីផ្សេងៗ ( ផ្លូវថ្នល់ ស្រះ ប្រឡាយ អាងទឹក ។ល។)

### 4.2.4 សិទ្ធិកាន់កាប់ដីធ្លី និង ទំហំដីកាន់កាប់

យោងទៅលើច្បាប់ដីដែលបានប្រកាសប្រើក្នុងឆ្នាំ 1992 បានចែងថាដីទាំងឡាយ គឺជាកម្មសិទ្ធិរបស់រដ្ឋាភិបាលហើយកសិករមានសិទ្ធិប្រើប្រាស់ដីទាំងនោះ ។

ដើម្បីរៀបចំផែនការកសិកម្ម ឬ ផែនការស្រោចស្រពអោយបានជាក់លាក់ប្រការសំខាន់នោះ គឺត្រូវយល់អោយបានច្បាស់អំពីសិទ្ធិកាន់កាប់ដីទាំងនោះ ។ ជាញឹកញាប់របទនាសម្ព័ន្ធ និង ស្ថាប័នរបស់រដ្ឋអំណាចមូលដ្ឋានបានប៉ះពាល់ដល់ការកាន់កាប់ដី និង បញ្រួស់ត្រឡប់មកវិញ ។ ចំនួនផ្ទៃក្រឡា និង ភាគរយគួរតែត្រូវបញ្ជាក់នៅប្រភេទជាបន្តបន្ទាប់ :

- ម្ចាស់ដី ( គ្រួសារដែលដាំដុះលើដីផ្ទាល់ខ្លួន )
- កសិករជួលដីគេ ( គ្រួសារដែលដាំដុះលើដីជួល )
- កសិករម្ចាស់ដី និង ជួលដីគេ ( គ្រួសារដែលដាំដុះលើដីខ្លួនឯងផង និង ដាំដុះលើដីដែលជួលគេផង ) និង
- ពលករកសិកម្ម ( គ្រួសារដែលគ្មានដីផ្ទាល់ខ្លួនហើយធ្វើការដោយលក់កំលាំងពលកម្ម )

ទំហំដីកាន់កាប់ក៏ជាកត្តាសំខាន់ដែរសំរាប់ផែនការកសិកម្ម ។ យោងលើទំហំដីដែលកាន់កាប់ការណែនាំអោយមានតុល្យភាពរវាងការធ្វើស្រែប្រើគ្រឿងយន្តកសិកម្ម និង ធ្វើស្រែប្រើកំលាំងពលកម្ម ដែលបញ្ហានេះគួរតែពិចារណាឱ្យបានដិតដល់ផងដែរ ។ ពត៌មានជាបន្តបន្ទាប់គួរតែត្រូវបានប្រមូល និង ចងក្រងលើទំហំដីដែលកាន់កាប់ :

- មធ្យមភាគ ឬ ទំហំដីកាន់កាប់ ( ហ.ត/គ្រួសារ)
- ទំហំដីកសិដ្ឋានអតិបរមា ( ហ.ត/គ្រួសារ) និង
- ទំហំដីកសិដ្ឋានអប្បបរមា ( ហ.ត/គ្រួសារ) ។

ក្នុងករណីដែលទំហំដីកាន់កាប់មានការខុសគ្នាច្រើននៅតាមទីកន្លែង ( ភូមិ ឃុំ ។ល។) ទំហំដីកាន់កាប់អាចនឹងបង្ហាញក្នុងលំដាប់ពិតប្រាកដ ( Ex : xx-yy ហ.ត/គ្រួសារ) ។

## 4.3 ការអនុវត្តន៍ការដាំដុះ

### 4.3.1 គំរូនៃការដាំដុះ និង ផលិតកម្ម

#### (1) ដំណាំគំរូបច្ចុប្បន្ន

ដំណាំគំរូគួររាប់បញ្ចូលពត៌មានជាបន្តបន្ទាប់ដែលបានបង្ហាញដូចជា :

- ឈ្មោះដំណាំដែលបានដាំ
- ផ្ទៃដីដែលបានដាំដំណាំនីមួយៗ
- រដូវលូតលាស់ និង ព្រឹត្តិការណ៍ដាំដុះ

ត្រូវកំណត់សំគាល់ពីផ្ទៃដីសរុបដែលជាន់គ្នាជាមួយផ្ទៃដីដាំដុះនៅក្នុងដីប្រើប្រាស់ ។ ការដាំដំណាំគំរូ នឹង បង្ហាញក្នុងរូបភាព 4-1 ។

ពត៌មានជាមូលដ្ឋានសំរាប់ផលិតដំណាំគំរូបច្ចុប្បន្ន អាចទទួលបានពីស្ថិតិ DAFF និង ការធ្វើសម្ភាសន៍ ។ សំរាប់គំរោងស្រោចស្រពខ្នាតតូច (200ហ.ត ឬ តិចជាង) គ្រាន់តែពីរ បីភូមិគ្រប់គ្រាន់ហើយការធ្វើសំភាសជាមួយមេភូមិ គឺជាវិធីល្អបំផុតសំរាប់ដឹងពីដីប្រើប្រាស់ក្នុងភូមិ ។ បន្ទាប់មកគួរជ្រើសរើសកសិករមួយចំនួននៅ អនុភូមិ (ក្រុម) ដើម្បីទទួលពត៌មានពីដំណាំគំរូ ។

ជាទូទៅស្រូវបានចែកជាបីប្រភេទ: i) ស្រូវស្រាល (ពូជទិន្នផលខ្ពស់ ii) ស្រូវកណ្តាល (ពូជក្នុងស្រុក) និង iii) ស្រូវធ្ងន់ (ពូជក្នុងស្រុក ) ។

ចំពោះ"ដំណាំផ្សេងៗ" ក្នុងការប្រើប្រាស់ដីផ្ទៃដីដាំដុះ និង រយះពេលរបស់ : i) ដំណាំបន្ទាប់បន្សំ (មិនមែនជាស្រូវហើយដាំដុះក្នុងស្រែនៅរដូវប្រាំង) ii) ដំណាំចំការ (ដំណាំដែលមិនដាំក្នុងដីស្រែ) iii) ដំណាំដែលរស់ឡើងវិញរាល់ឆ្នាំ និង iv) ដំណាំហូបផ្លែនឹងត្រូវបានបញ្ជាក់ ។

ដំណាំណាដែលកសិករចូលចិត្ត គួរតែត្រូវបញ្ជាក់នៅពេលដែលធ្វើសម្ភាសន៍ ។ ក្នុងប្រទេសកម្ពុជាប្រជាកសិករចូលចិត្តធ្វើស្រូវកណ្តាល និង ស្រូវធ្ងន់ (ពូជក្នុងស្រុក) ពីព្រោះតែ"រសជាតិ"របស់វាហើយទោះបីជាទិន្នផលទាបជាងពូជដទៃទៀតក៏ដោយ ។ ការជ្រើសរើសរបស់កសិករ គួរតែយកមកអនុវត្តតាមដែរក្នុងដំណាំគំរូដែលបានស្នើ ។

#### (2) ផលិតកម្ម និង ទិន្នផល

ផលិតកម្ម និង ទិន្នផលរបស់ដំណាំនីមួយៗដែលបានដាំដុះបច្ចុប្បន្នគួរតែបញ្ជាក់ ។ ប្រសិនបើកសិករមួយចំនួនមិនដែលស្គាល់ឯកត្តារបស់មាឌ (ម$^3$) និង ទំងន់ (គ.ក) យកល្អត្រូវសួរពួកគាត់ថា "តើអ្នកច្រូតកាត់ស្រូវបានប៉ុន្មានកញ្ជើ (ឬ បាវ ) ពីស្រែ ?" ។

ផលិតកម្ម និង ទិន្នផល គួរតែបញ្ជាក់ទៅតាមរដូវដោយយោងទៅលើដំណាំគំរូ ។

### 4.3.2 ទុនចំណាយកសិកម្ម

ទុនចំណាយកសិកម្មមាន : i) ពូជ ii) ជី iii) ថ្នាំគីមីដូចជាថ្នាំសំលាប់សត្វល្អិត ។ ការប្រើប្រាស់ពូជតាមពូជដំណាំ (គ.ក/ហ.ត) កំរិតនៃការប្រើជី និង ថ្នាំគីមីតាមប្រភេទ (គ.ក/ហ.ត) គួរតែត្រូវបានបញ្ជាក់ ។ តំលៃសំភារៈនៃទុនទាំងអស់នោះក៏គួរតែបញ្ជាក់នៅទីផ្សារដែលជិតបំផុត (វិស័យឯកជន) និង អ្នកផ្គត់ផ្គង់ដែលទ្រទ្រង់ដោយរដ្ឋាភិបាលប្រសិនបើមាន ។

### 4.3.3 អនុវត្តន៍ការដាំដុះ

មុខការជាបន្តបន្ទាប់គួរតែបញ្ជាក់នៅក្នុងការអនុវត្តទីការដាំដុះ :

- ពលកម្មការរៀបចំដី ការដកស្ទូង និង ច្រូតកាត់តាមប្រភេទពលកម្ម ( ជួល ឬ គ្រួសារ)
- ចំនួនសត្វពាហនៈសំរាប់ភ្ជួររាស់
- គ្រឿងយន្តកសិកម្ម ឧបករណ៏សំរាប់រៀបចំដាំដំណាំ ប្រដាប់ប្រដារធ្វើស្រែ ។
- របៀបរៀបចំដីដកស្ទូង និង ច្រូតកាត់
- ការដាក់ជី និង ថ្នាំគីមី ( តាមបរិមាណ និង ពេលវេលាកំណត់)
- ការដកស្មៅ
- ការកំចាត់សត្វចង្រៃ និង
- ការស្រោចស្រព ស្រោចទឹក

### 4.3.4 បសុសត្វ

បសុសត្វ គឺជាប្រភពចំណូលដ៏ធំបំផុតសំរាប់គ្រួសារកសិករជាច្រើន ។ ចំនួនបសុសត្វជាញឹកញាប់បានផ្តល់នូវលំដាប់កំរិតប្រាក់ចំណូលរបស់គ្រួសារកសិករ ។ គ្រួសារកសិករក្រីក្រភាគច្រើនមិនអាចផលិតស្រូវអោយបានគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនបានឡើយ ពួកគាត់ត្រូវលក់ស្រូវដែលច្រូតកាត់បានដើម្បីយកប្រាក់ទៅទិញសំភារៈចាំបាច់ប្រចាំថ្ងៃដូចជា សំលៀកបំពាក់ ថ្នាំពេទ្យ ការសិក្សា ឧស ។ ល ។

ពត៌មានជាបន្តបន្ទាប់គួរតែប្រមូលបានអំពីបសុសត្វមាន :

- ចំនួនបសុសត្វតាមប្រភេទ ( ក្បាល/គ្រួសារ )
- រយៈពេលចិញ្ចឹមតាមប្រភេទ ( ខែ )
- តំលៃទិញតាមប្រភេទ ( រៀល/ក្បាល )
- តំលៃលក់តាមប្រភេទ ( រៀល/ក្បាល )

- វិធីរកចំណី
- ការអោយចំណីតាមប្រភេទ ( គ.ក/ក្បាល )
- តំលៃចំណីសត្វក្នុងមួយខែ ( រៀល/ខែ )

## 4.4 សេវាកម្មផ្សព្វផ្សាយកសិកម្ម

សេវាទ្រទ្រង់កសិកម្ម ដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍កសិកម្ម ។ សេវាដែលអាចរកបានគួរតែបញ្ជាក់ អោយបានច្បាស់មុនពេលអនុវត្តន៍ផែនការអភិវឌ្ឍន៍ដើម្បីស្នើសុំសេវាទ្រទ្រង់ដែលត្រូវការ ។

សេវាផ្សព្វផ្សាយមាន : i) ណែនាំអំពីដំណាំ និង ការគ្រប់គ្រងកសិដ្ឋាន ( បច្ចេកទេសទ្រទ្រង់កសិកម្ម) និង ii) សេវាឥណទាន ។ ពត៌មានជាបន្តបន្ទាប់គួរតែបញ្ជាក់នៅតំបន់ស្នើសុំ :

- ការចាត់តាំង និង មុខងាររបស់ MAFF (DAFF) ខេត្តទៅលើសេវាផ្សព្វផ្សាយ ។
- ចំនួនបុគ្គលិកផ្សព្វផ្សាយ និង ឯកទេសរបស់ពួកគេដែលទទួលបន្ទុកក្នុងតំបន់ ( នឹងត្រូវបញ្ជាក់នៅDAFF)
- សកម្មភាព និង ភាពញឹកញាប់ ឬ តារាងពេលវេលានៃការចុះមើលស្រែដោយបុគ្គលិកផ្សព្វផ្សាយ ( នឹងត្រូវបញ្ជាក់នូវ DAFF )
- សកម្មភាព និង ភាពញឹកញាប់នៃការចុះមើលស្រែរបស់បុគ្គលិកផ្សព្វផ្សាយ ( នឹងត្រូវបញ្ជាក់នៅក្នុងតំបន់គំរោង )
- សេវាឥណទានដែលអាចរកបានទាំងឯកជនទាំងសាធារណៈ និង តំបន់ផ្សេងៗ ( ដូចជា NGO) និងលក្ខខ័ណ្ឌរបស់ពួកគេ ( អណិត្តសង អត្រាការប្រាក់ ។ល។)
- ការផ្សព្វផ្សាយដែលរំពឹងទុកដោយកសិករ ( នឹងត្រូវបញ្ជាក់នៅក្នុងតំបន់គំរោង ) និង
- គំរោងដទៃទៀត និង/ឬ កម្មវិធីផ្សព្វផ្សាយដោយ NGO និង IOs ។

## 4.5 ក្រោយពេលការច្រូតកាត់ និង ទីផ្សារ

### 4.5.1 ក្រោយពេលការច្រូតកាត់

ដំណើរការក្រោយពេលច្រូតកាត់ត្រូវធ្វើជាពីរដំណាក់កាល គឺដំណាក់កាលរបស់អ្នកផលិត និង ដំណាក់កាលចែកចាយ ។ ការច្រូតកាត់ និង ការបោកបែន ការហាលថ្ងៃ និង ការទុកដាក់ត្រូវធ្វើដោយអ្នកផលិត ហើយការកិនស្រូវជាទូទៅត្រូវធ្វើដោយឈ្មួញកណ្តាល អ្នកលក់ដុំ និង អ្នកលក់រាយ ។ ចំណាយសំរាប់កែច្នៃ និង ចំណាយផ្សេងៗបានប៉ះពាល់ដោយផ្ទាល់នៅនឹងថ្លៃលក់កសិផលនៅនឹងកន្លែង ហើយបច្ចុប្បន្នប្រពន្ធ័នៃដំណើរការច្រូតកាត់គួរតែយល់អោយបានច្បាស់ដើម្បីបង្កើនប្រាក់ចំណូលសំរាប់កសិករ ។ ចំណុចការជាបន្តបន្ទាប់នឹងត្រូវបញ្ជាក់ពីបញ្ហាក្រោយពេលច្រូតកាត់មានដូចជា :

- វិធីច្រូតកាត់ និង បោកបែន
- ថ្លៃបោកបែន
- ការបាត់បង់ពេលច្រូតកាត់ និង បោកបែន
- វិធីហាលស្រូវ
- ការទុកដាក់ដែលអាចរកបាន
- ការបាត់បង់ពេលទុកដាក់
- ថ្លៃកិនស្រូវ និង
- បញ្ហាលើដំណើរការក្រោយពេលច្រូតកាត់

### 4.5.2 ទីផ្សារ

បណ្តាញទីផ្សារគួរតែបញ្ជាក់សំរាប់ដំណាំនីមួយៗ ជាពិសេសសំរាប់ដំណាំ និង បន្លែដែលស្នើឡើងថ្មី ។ មុខការជាបន្តបន្ទាប់នឹងត្រូវបញ្ជាក់អំពីទីផ្សារ :

- ថ្លៃលក់កសិផលនៅនឹងកន្លែងរបស់ផលិតផលនីមួយៗ
- ផ្សារនៅជិតបំផុតទៅតាមផលិតផល រួមទាំងបសុសត្វ និង
- ចំណាយដឹកជញ្ជូនទៅផ្សារជិតបំផុត

## 4.6 សេដ្ឋកិច្ចកសិកម្ម

### 4.6.1 ថវិកាដំណាំ

ថវិការដំណាំ ជាគោលនៅតំបន់ដែលបានកំណត់ គួរតែត្រូវបានបង្ហាញដូច្នេះថាគោលដៅរបស់ផែនការកសិកម្ម នឹងត្រូវបានរៀបចំដោយត្រឹមត្រូវ ។ ថវិកាដំណាំមាន : i) ចំណូលដុល (តំលៃផលិតផល) ii) ចំណាយផលិតកម្ម (ពូជ ជី ទុនផ្សេងៗ កំលាំងពលកម្ម សត្វអូសទាញ គ្រឿងម៉ាស៊ីន ។ល។ និង iii) ប្រាក់ចំនេញ ។

ចំណាយផលិតកម្មអាចប៉ាន់ស្មានបានដោយយោងទៅលើទិន្នន័យអំពីទុនចំណាយកសិកម្ម (អនុផ្នែក 4.3.2) និង អនុវត្តន៍ការដាំដុះ (អនុផ្នែក 4.3.3) ។ ចំណូលដុលអាចប៉ាន់ស្មានបានពីមធ្យមភាគផលិតកម្ម និង តំលៃនៅកសិដ្ឋាន(អនុផ្នែក 4.3.2) ។ ថវិកាដំណាំនឹងមានសង្ខេបនៅក្នុងតារាងតុល្យការដែលជាគំរូផ្តល់អោយក្នុងតារាង 4.2 ។ លក្ខខ័ណ្ឌ និង ការកំណត់របស់ការប៉ាន់ស្មាននឹងរៀបរាប់យ៉ាងច្បាស់លាស់ក្នុងតារាងតុល្យការ ។

### 4.6.2 សេដ្ឋកិច្ចគ្រួសារ

កំរិតជីវភាពគ្រួសារអាចវិភាគតាមរយៈប្រាក់ចំណូល និង ប្រាក់ចំណាយ ។ ប្រាក់ចំណូលតិចតួចសំរាប់គ្រួសារក្រីក្រ ហើយប្រាក់ចំណាយសំរាប់ទិញសំភារៈប្រើប្រាស់សំរាប់ការរស់នៅរបស់ពួកគេ ក៏តិចតួចដែរ ។ ម្យ៉ាងវិញទៀតនៅពេលកំរិតជីវភាពត្រូវបានកែលំអរ ការចំណាយសំរាប់ជីវភាព ក៏នឹងកើនឡើងដែរ ។ ដូច្នេះសេដ្ឋកិច្ចគ្រួសារនឹងត្រូវបានរៀបតាមលំដាប់លំដោយសំរាប់វាយតំលៃការចំណាយរបស់គំរោង ។

ចំពោះការវាយតំលៃនេះ ការស្ទាបស្ទង់ពីការផ្លាស់ប្តូររបស់សេដ្ឋកិច្ចគ្រួសារមុន និង ក្រោយគំរោងគួរតែត្រូវបានអនុវត្ត ។ ការវាយតំលៃជនបទរហ័ស ( RRA យោងទៅជំពូក 19 "ផែនការចូលរួម") គឺជាវិធីដ៏សក្តិសមសំរាប់ការស្ទាបស្ទង់ ។ ចំពោះប្រាក់ចំណូល និង ចំណាយផលិតផលសំរាប់ប្រើប្រាស់ត្រូវប្តូរជាតំលៃទឹកប្រាក់សំរាប់ប្រាក់ចំណូល និង ចំណាយ ។ ប្រាក់ចំណូល និង ចំណាយផលិតផលសំរាប់ប្រើប្រាស់ត្រូវប្តូរជាតំលៃទឹកប្រាក់ និង ចំណាយ ។ ប្រាក់ចំណូល និង ចំណាយនឹងមានកត្តាមួយចំនួនជាបន្តបន្ទាប់ :

**តារាង កត្តានៃប្រាក់ចំណូល និង ចំណាយ**

| កត្តា | | វាយសេចក្តី |
|---|---|---|
| ចំណូលដុល | ចំណូលកសិកម្ម | ស្រូវ ( សាច់ប្រាក់តាមប្រភេទ )<br>បសុសត្វ ( " )<br>បន្លែ ( " )<br>ផ្លែឈើ ( " ) |
| | ចំណូលក្រៅកសិដ្ឋាន | ពលកម្មនៅកសិដ្ឋាន ( រួមទាំងពលកម្មប្រវាស់គ្នាបណ្តោះអាសន្ន )<br>ពលកម្មក្រៅកសិដ្ឋាន ( រួមទាំងពលកម្មប្រវាស់គ្នាបណ្តោះអាសន្ន )<br>លក់ធនធានព្រៃឈើដែលកើតឯង ( ឧស ឈើអារ ។ល។)<br>ជំនួញឯកជន<br>បៀវត្ស ( អធិផ្តែ្ខយ៍ កុងត្រា ។ ល ។ )<br>ផ្សេងៗ |
| | បំណុល និង កម្ចី | សាច់ប្រាក់<br>តាមប្រភេទ ( ស្រូវ, ជ្រូក ។ ល ។) |
| ចំណាយដុល | ចំណាយផលិតកម្ម | ពូជ<br>ជី<br>ថ្នាំគីមី<br>ពលកម្ម ( គ្រួសារ ជួល )<br>សត្វអូសទាញ ( គ្រួសារ ជួល )<br>ម៉ាស៊ីន<br>ថ្លៃទឹក (ISF) ទំហំតូចបន្តិច<br>ប្រេងឥន្ធនៈ<br>ផ្សេងៗ |
| | ចំណាយសំរាប់ជីវភាព | ថែរក្សាសុខភាព<br>សំលៀកបំពាក់<br>ការសិក្សា<br>ការដឹកជញ្ជូន<br>អាហារ ( អាហារចំបាច់ )<br>អាហារផ្សេងៗ ( មិនចាំបាច់ តែ ថ្នាំជក់ ។ ល ។)<br>ប្រេងឥន្ធនៈ<br>ពន្ធដារ<br>ផ្សេងៗ |
| | វិនិយោគទុន | សាច់ប្រាក់<br>តាមប្រភេទ ( ស្រូវ ជ្រូក ។ ល ។) |
| ការសន្សំប្រាក់ | | សាច់ប្រាក់<br>តាមប្រភេទ ( ស្រូវ ជ្រូក ។ ល ។) |